

# កំណត់សាវតារស្តីពីយុត្តិធម៌អនីតិជនក្នុងប្រទេសកម្ពុជា និង ការវិភាគទៅលើមូលហេតុដែលបណ្ដាលឲ្យចំនួនអនីតិជនជាប់ក្នុងពន្ធនាគារកើនឡើង និងថយចុះ

ខែកញ្ញា ឆ្នាំ២០១៧

unicef | for every child
CAMBODIA

# មាតិកា

សេចក្តីថ្លែងអំណរគុណ ....2
បរិបទ និងគោលបំណងនៃកំណត់សារវតារនេះ ....3
បរិបទ និងស្ថានភាពយុត្តិធម៌អនីតិជនក្នុងប្រទេសកម្ពុជា ....4
ការកើនឡើងនៃតួលេខអនីតិជនជាប់ឃុំ ....9
តើហេតុអ្វីបានជាមានការថយចុះចំនួនអនីតិជនជាប់ឃុំ នៅចន្លោះឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ ....9
តើហេតុអ្វីបានជាថ្មីៗនេះមានការកើនឡើងនូវចំនួនអនីតិជនជាប់ឃុំ? ....12
- គ្រឿងញៀន ....12
- កង្វះធនធាន ....13
- ការថយចុះជំនួយផ្នែកយុត្តិធម៌ ....13
- កង្វះការយល់ដឹងនៅតាមសហគមន៍ ....14
- អវត្តមានលិខិតបញ្ជាក់កំណើត ....14

កត្តាជម្រុញ និងឧបសគ្គក្នុងការអនុវត្តកម្មវិធីបង្វែរ ចំពោះករណីអនីតិជនទំនាស់នឹងច្បាប់ ....14
ផែនការសកម្មភាពជាមូលដ្ឋាន ....16

## សេចក្តីថ្លែងអំណរគុណ

ឯកសារនេះត្រូវបានផ្សព្វផ្សាយដោយអង្គការUNICEFប្រចាំប្រទេសកម្ពុជា និងត្រូវបានសរសេរដោយកញ្ញា Ines PROVOOST ជាអ្នកហាត់ការ និងលោក លឹម វណ្ណា មន្ត្រីកិច្ចការពារកុមារ។ សូមថ្លែងអំណរគុណជាពិសេសដល់ដៃគូរបស់អង្គការUNICEFប្រចាំប្រទេសកម្ពុជាដែលបានចូលរួមផ្តល់ជាយោបល់និងជួយត្រួតពិនិត្យ។ រចនាឯកសារដោយអ្នកស្រី សឿម យ៉ូរ៉ា។

## បរិបទ និងគោលបំណងនៃកំណត់សារតារនេះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើតផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិការរយៈពេលបីឆ្នាំ ដើម្បីចង្អុលបង្ហាញពីការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនក្រោមជំនួយបច្ចេកទេសពីអង្គការ Children's Rights International, Plan International, និងUNICEF។

កំណត់សារតារនេះគូសបញ្ជាក់អំពីសាវតា និងការវិវឌ្ឍន៍យុត្តិធម៌អនីតិជនក្នុងប្រទេសកម្ពុជា។ វាជាការចងក្រងឯកសារមួយដើម្បីផ្តល់ការយល់ដឹង និងការវិភាគលើកត្តាដែលបណ្តាលឲ្យមានការកើនឡើងចំនួនអនីតិជនជាប់ឃុំ ជាពិសេសការកើនឡើងក្នុងពេលថ្មីៗនេះដែលមានចំនួនដល់ទៅ៩០៧នាក់ គិតត្រឹមថ្ងៃទី១៥ខែមករាឆ្នាំ២០១៧ នេះបើតាមនិន្នន័យថ្មីដែលផ្តល់ឲ្យដោយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។ រាជរដ្ឋាភិបាលកម្ពុជានិងUNICEFកម្ពុជា បានចុះហត្ថលេខាលើផែនការសកម្មភាពកម្មវិធីប្រចាំប្រទេសកាលពីខែកុម្ភៈឆ្នាំ២០១៦។ ការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពដទៃទៀតនោះ គឺកាត់បន្ថយចំនួនអនីតិជនក្នុងពន្ធធនាគារឱ្យបាន៥០ភាគរយ ត្រឹមចុងឆ្នាំ២០១៨ ដោយផ្អែកលើទិន្នន័យអនីតិជនជាប់ឃុំចំនួន៨នាក់ក្នុងចំណោមអនីតិជន១០០,០០០នាក់។ កត្តាជម្រុញចម្បងដើម្បីសម្រេចបានគោលដៅនេះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលមានគោលបំណងអនុវត្តប្រព័ន្ធយុត្តិធម៌អនីតិជនជាក់លាក់ប្រកបដោយប្រសិទ្ធិភាព និងដើម្បីលើកទឹកចិត្តព្រមទាំងសម្របសម្រួលឱ្យមានការបង្វែរអនីតិជនទំនាស់នឹងច្បាប់ ក៏ដូចជាគាំទ្រដល់ការស្តារនីតិសម្បទារបស់ពួកគេ និងសមាហរណកម្មពួកគេត្រឡប់ទៅសហគមន៍វិញ។

ឯកសារកំណត់សារតារនេះមានគោលដៅផ្តល់គន្លឹះសម្រាប់ការយល់ដឹងអំពីស្ថានភាពយុត្តិធម៌អនីតិជន និងបញ្ហាប្រឈមជាក់លាក់ក្នុងវិស័យនេះនៅក្នុងប្រទេសកម្ពុជា។ ឯកសារនេះក៏គូសបញ្ជាក់ផងដែរអំពីកត្តានានាដែលនាំឲ្យមានការថយចុះនិងកើនឡើងចំនួនអនីតិជនក្នុងពន្ធធនាគារនៅចន្លោះឆ្នាំ២០១០និង២០១៧។ នៅទីបញ្ចប់នៃឯកសារនេះ មានផ្តល់ជាអនុសាសន៍ និងសកម្មភាពជាយុទ្ធសាស្ត្រដែលអាចនាំទៅដល់ការកាត់បន្ថយចំនួនអនីតិជនក្នុងពន្ធនាគារ។




ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលត្រូវបានរង់ចាំអស់រយៈពេលជាយូរ ហើយដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ ព្រមទាំងត្រូវបានឡាយព្រហស្តលេខាប្រកាសដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រឹត្យនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅការពារអនីតិជនមានទំនាក់ទំនង ឬ ទំនាស់នឹងច្បាប់ ហើយវាក៏នឹងផ្តល់នូវប្រព័ន្ធយុត្តិធម៌អនីតិជនមួយជាក់លាក់ ដែលធានាការគោរពសិទ្ធិរបស់ពួកគេ។

ជាការពិតណាស់ សិទ្ធិរបស់អនីតិជនដែលជាជនសង្ស័យ ឬជាជនជាប់ចោទប្រព្រឹត្តបទល្មើស មានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ក៏ដូចជាវិធានអន្តរជាតិដទៃទៀតដែលកម្ពុជាជាហត្ថលេខីនោះផងដែរ។ ហេតុនេះ ច្បាប់ថ្មីស្តីពីយុត្តិធម៌អនីតិជននេះមានភាពចាំបាច់ណាស់ ដើម្បីធានាបានថាប្រព័ន្ធយុត្តិធម៌អនីតិជនកម្ពុជាអនុលោមតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

តើការប្តេជ្ញាចិត្តជាអន្តរជាតិមានចែងពីអ្វីខ្លះ?

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ អនីតិជន/កុមារទំនាស់នឹងច្បាប់គួរទទួលបានការប្រព្រឹត្តដោយអនុលោមតាមអាយុរបស់ពួកគេ ដោយត្រូវពិចារណាលើការធ្វើសមាហរណកម្មពួកគេត្រឡប់ទៅសង្គមវិញ។ អនុសញ្ញាបានចែងយ៉ាងច្បាស់ថា ការឃុំខ្លួនអនីតិជនគប្បីជាជម្រើសចុងក្រោយបំផុត និងក្នុងរយៈពេលខ្លីបំផុតដែលសមស្រប (មាត្រា ៣៧)។

បន្ថែមលើនេះទៀត *វិធានអង្គការសហប្រជាជាតិស្ដីពីកិច្ចការពារកុមារដែលត្រូវបានដកហូតសេរីភាព*[1] បានចែងក្នុងមាត្រា១ និងមាត្រា២ ថា ប្រព័ន្ធយុត្តិធម៌អនីតិជនគប្បីលើកកម្ពស់សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន។ ការដកហូតសេរីភាពរបស់អនីតិជន គប្បីអនុលោមតាមគោលការណ៍ និងនីតិវិធីដែលមានចែងនៅក្នុងវិធានទាំងនេះ និងនៅក្នុង*បទដ្ឋានវិធានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងលើយុត្តិធម៌អនីតិជន (វិធានទីក្រុងប៉េកាំង*[2]*)*។ បើយោងតាមវិធាននេះ ការដកហូតសេរីភាពរបស់អនីតិជនណាម្នាក់គប្បីជាជម្រើសចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុតទៅតាមការចាំបាច់ និងចំពោះតែករណីពិសេសប៉ុណ្ណោះ។

*តើស្ថានភាពទូទៅនាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជាមានលក្ខណៈបែបណា?*

| | |
|---|---|
| ចំនួនអ្នកជាប់ពន្ធនាគារសរុប (រាប់បញ្ចូលអ្នកជាប់ឃុំបណ្ដោះអាសន្នមុនជំនុំជម្រះ) | ២២ ៨១៨ នាក់<br>ទិន្នន័យអគ្គនាយកដ្ឋានពន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៧ |
| អត្រាចំនួនអ្នកជាប់ពន្ធនាគារ (ក្នុងចំណោមប្រជាជន ១០០,០០០ នាក់) | ១៣៨ នាក់<br>ផ្អែកលើអត្រាប្រជាជនប៉ាន់ប្រមាណសរុបចំនួន ១៥,៩៥ លាននាក់ នៅចុងឆ្នាំ២០១៦ (យោងតាមតួលេខអង្គការសហប្រជាជាតិ) |
| អ្នកជាប់ពន្ធនាគារជាស្ត្រី | ១,៨៧៨ នាក់ (៨%នៃចំនួនអ្នកជាប់ពន្ធនាគារសរុប)<br>ទិន្នន័យអគ្គនាយកដ្ឋានព័ន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ |
| អ្នកជាប់ពន្ធនាគារជាអនីតិជន | ៩០៧ នាក់ (៤% នៃចំនួនអ្នកជាប់ពន្ធនាគារសរុប)<br>ទិន្នន័យអគ្គនាយកដ្ឋានព័ន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ |
| អ្នកជាប់ពន្ធនាគាជាស្ត្រីពពោះ | ៤៦ នាក់<br>ទិន្នន័យអគ្គនាយកដ្ឋានព័ន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ |
| អនីតិជនតាមម្ដាយក្នុងពន្ធនាគារ | ៨១ នាក់<br>ទិន្នន័យអគ្គនាយកដ្ឋានព័ន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ |
| អ្នកជាប់ពន្ធនាគារជាជនបរទេស | ៩៥០ នាក់(៤%នៃចំនួនអ្នកជាប់ពន្ធនាគារសរុប)<br>ទិន្នន័យអគ្គនាយកដ្ឋានព័ន្ធនាគារៈគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ |
| ចំនួនគ្រឹះស្ថាន/មណ្ឌល | ២៨<br>(យោងតាមរបាយការណ៍របស់អង្គការ*LICADHO*) |

[1] Resolution adopted by the United Nations General Assembly; 'United Nations Rules for the Protection of Juveniles Deprived of Their Liberty', A/RES/45/113, 14 December 1990.
[2] Resolution adopted by the United Nations General Assembly; 'United Nations Standard Minimum Rules for the Administration of Juvenile Justice ('The Beijing Rules')', A/RES/40/33, 29 November 1985.

| | |
|---|---|
| ចំណុះផ្លូវការរបស់ពន្ធនាគារទាំងអស់នៅកម្ពុជាដែលអាចដាក់អ្នកទោសបាន | ៨,៥០០ នាក់ ១៥.១០.២០១៥ (តាមឯកសាររបស់ *International Centre for Prison Studies*[3]) |
| កម្រិតនៃការផ្ទុកអ្នកជាប់ឃុំ | ១៦៨% នេះជាចំនួនភាគរយនៃការកើនឡើង ដោយធ្វើការធៀបរវាងចំនួនជាក់ស្តែងនៃអ្នកជាប់ធន្ធនាគារទៅនឹង ចំណុះផ្លូវការរបស់ពន្ធនាគារ ដោយគិតត្រឹម១៥.១០.២០១៥ |

ថ្វីបើក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ កំណត់នីតិភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌត្រឹមអាយុ ១៨ ឆ្នាំឡើងទៅក៏ដោយ(មាត្រា ៣៨) ក៏អនីតិជនអាចត្រូវបានតុលាការពិចារណាឲ្យទទួលទណ្ឌកម្មព្រហ្មទណ្ឌបានដែរចាប់ពីអាយុ ១៤ ឆ្នាំឡើងទៅ (មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ) ដោយយោងទៅតាមកាលៈទេសៈនៃបទល្មើស។ ជាគោលការណ៍ អនីតិជនមិនត្រូវបានចាត់ទុកថាមានភាពចាស់ទុំ និង/ឬមានការទទួលខុសត្រូវគ្រប់គ្រាន់ និងវិនិច្ឆ័យចំពោះទង្វើរបស់ខ្លួនដូចមនុស្សពេញវ័យឡើយ។ ប៉ុន្តែ ដោយសារតែខ្វះប្រព័ន្ធយុត្តិធម៌អនីតិជនដ៏រឹងមាំ និងអវត្តមាននៃច្បាប់យុត្តិធម៌អនីតិជន អនីតិជនមួយចំនួនដែលបានប្រព្រឹត្តិបទល្មើសលហុ ដូចជាការលួច ឬការប្រើប្រាស់គ្រឿងញៀនជាដើម ត្រូវបានជំនុំជម្រះ និងដាក់ទោសដូចមនុស្សពេញវ័យដែរ។ យោងតាមការវិភាគរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អ្នកជំនាញការអង្គការសង្គមស៊ីវិលធ្វើការប៉ាន់ប្រមាណថា រហូតដល់ ៥០% នៃអនីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ត្រូវបានគេអនុវត្តមកលើខ្លួនដូចជាមនុស្សពេញវ័យដែរនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[4]។ ដោយសារតែការបណ្តុះបណ្តាលពុំទាន់គ្រប់គ្រាន់ស្តីពីរបៀបរបបនៃការអនុវត្តមកលើជនល្មើសជាអនីតិជន និងការយល់ដឹងរបស់តុលាការនៅមានកម្រឹត អនីតិជនដែលត្រូវបានកំណត់ថាមានទោស ត្រូវបានសម្រេចឱ្យជាប់ពន្ធនាគារស្ទើរតែគ្រប់ករណីទាំងអស់ ដោយអ្នកខ្លះត្រូវជាប់ឃុំហួសរយៈពេលដែលបានកំណត់ ដែលនេះគឺជាការរំលោភបំពានមួយទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ថ្វីបើមានកិច្ចខិតខំ និងការព្យាយាមរបស់ពន្ធនាគារជាច្រើនដើម្បីបំបែកអនីតិជនចេញទាំងស្រុងពីអ្នកជាប់ឃុំជានីតិជនក្តី ប៉ុន្តែតាមការបញ្ជាក់របស់អង្គការលីកាដូ (LICADHO) ស្ទើរតែ ៤០% នៃអនីតិជនទាំងអស់ត្រូវជាប់ពន្ធនាគារនៅក្នុងបរិវេណជាមួយនីតិជន។ ជារឿយៗ ការបំបែកអនីតិជនចេញពីនីតិជន តែងតែអាស្រ័យលើចំនួនអ្នកទោសក្នុងពន្ធនាគារ ហើយការបំបែកនេះរឹតតែពុំអាចធ្វើទៅបាន ក្នុងខណៈដែលចំនួនអ្នកទោសកើនឡើងដល់១៦៨ភាគរយគឺ ២២,៨១៨នាក់បើគិតត្រឹមថ្ងៃទី១៥មករា២០១៧(សូមមើលរូបភាពទី១) ចំណែកឯចំណុះជាផ្លូវការរបស់ពន្ធនាគារដែល

[3] World Prison Brief Data: http://www.prisonstudies.org/country/cambodia
[4] Cambodian Centre for Human Rights, 'Children in the Cambodian criminal justice system', CCHR Briefing Note, October 2014.

អាចផ្ទុកអ្នកទោសបាន មានត្រឹម៨,៥០០នាក់[5]។ ចំនួនអ្នកទោសជាអនីតិជន បានឈានដល់កម្រិតដែលមិនធ្លាប់មានពីមុនមក។ គិតត្រឹមថ្ងៃទី១៥មករា២០១៧ ទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារបានបង្ហាញថាមានអនីតិជនជាប់ពន្ធនាគាររហូតដល់ទៅ៩០៧នាក់ ដែលចំនួននេះធ្វើឲ្យមានការកើនឡើងចំនួនអ្នកជាប់ពន្ធនាគារសរុបដល់ទៅ១.២ភាគរយ បើធៀបទៅខែមករា២០១៦។




ប្រភពព័ត៌មាន៖ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគារ
មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាអំពីពន្ធនាគារ

ប្រព័ន្ធយុត្តិធម៌អនីតិជនរបស់កម្ពុជា បានផ្តោតការយកចិត្តទុកដាក់ជាចំបងលើការដាក់ទោសទណ្ឌ ដោយសារខ្វះប្រព័ន្ធនិងខ្វះការយល់ដឹងអំពីសេចក្តីត្រូវការរបស់អនីតិជន ដែលជាហេតុនាំឲ្យពុំសូវមានការស្តារនីតិសម្បទាប្រកបដោយជោគជ័យនៅក្នុងសហគមន៍និងសង្គម។ ជាក់ស្តែង ការដាក់ទោសអនីតិជន តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ អាចបង្កើនលទ្ធភាពដែលធ្វើឱ្យអនីតិជនធ្លាក់ចូលទៅក្នុងការកំណត់អត្តសញ្ញាណខ្លួនឯងថាមានពិរុទ្ធភាព និងប្រព្រឹត្តបទល្មើសឡើងវិញ ហើយអាចជាបទល្មើសធ្ងន់ធ្ងរជាងមុនផងក៏មាន។ ដោយហេតុនេះហើយ ទើបគេចាំបាច់ត្រូវធ្វើអន្តរាគមន៍ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ដើម្បីទប់ស្កាត់ ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជនទាំងនោះទៅក្នុងសង្គមវិញមុនពេលពួកគេក្លាយជាឧក្រិដ្ឋជន។

[5] World Prison Brief, ‘Data Cambodia’, <www.prisonstudies.org/country/cambodia>, accessed 6 April 2017

ការផ្លាស់ប្តូរជាវិជ្ជមាន បានទទួលការគាំទ្រជាយូរមកហើយពីអង្គការ UNICEF និង ដៃគូ ហើយជាលទ្ធផលគួឲ្យកត់សម្គាល់ យើងទទួលបានការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលច្បាប់នេះផ្តោតការយកចិត្តទុកដាក់លើការបង្វែរអនីតិជនដែលត្រូវបានចោទថាមានពិរុទ្ធភាព ជាជាងការដាក់ទណ្ឌកម្មលើពួកគេ។ ការបង្វែរអនុញ្ញាតិឱ្យជនល្មើសជាអនីតិជនអាចទទួលបានការស្តារនីតិសម្បទា ដែលនេះហើយជាគោលដៅចំបងរបស់យុត្តិធម៌អនីតិជន ពោលគឺរក្សាចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយគ្រួសារ និងសហគមន៍របស់ពួកគេ ហើយការរក្សាចំណងទាក់ទងនេះ អាចកាត់បន្ថយលទ្ធភាពនៃការប្រព្រឹត្តបទល្មើសម្តងទៀតនាពេលអនាគត ហើយក៏អាចផ្តល់កិច្ចការពារដល់អនីតិជនបានផងដែរ។ មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ យោងទៅការអនុវត្តវិធានការបង្វែរ ថាជាចំណាត់ការដ៏ប្រសើរបំផុត ដោយបញ្ជាក់ថា នៅពេលដែលសមស្រប វិធានការទាំងឡាយណាដែលមិននាំឱ្យឈានទៅដល់ដំណើរការនីតិវិធីតុលាការ គប្បីយកមកអនុវត្ត ដែលក្នុងនោះមានដូចជា ការថែទាំ ការចង្អុលបង្ហាញ ការប្រឹក្សាយោបល់ ការព្យួរទោសមានលក្ខខណ្ឌ ការងារសហគមន៍ ឬការអប់រំជាដើម ដែលទាំងនេះគឺជាឧទាហរណ៍មួយចំនួននៃវិធានការដែលត្រូវយកមក អនុវត្ត។ ឥឡូវនេះ បញ្ហាប្រឈមគឺការអនុវត្តឲ្យមានប្រសិទ្ធិភាពនូវច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ ដើម្បីឲ្យកុមារទទួលបាន ផលប្រយោជន៍ពីច្បាប់នេះ។

# ការកើនឡើងនៃតួលេខអនីតិជនជាប់ឃុំ




ប្រភពព័ត៌មាន៖ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០១៧

ទិន្នន័យខែវិច្ឆិកា២០១៦ ៖ សាលាឧទ្ធរណ៍

## តើហេតុអ្វីបានជាមានការថយចុះចំនួនអនីតិជនជាប់ឃុំ នៅចន្លោះឆ្នាំ២០១០ ដល់ឆ្នាំ២០១៤

យោងតាមទិន្នន័យផ្តល់ឲ្យដោយក្រសួងមហាផ្ទៃ នៅចន្លោះឆ្នាំ២០១០ ដល់ ២០១៤ មានការថយចុះ ៥៦,៥ ភាគរយ នៃចំនួនអនីតិជនក្នុងកន្លែងឃុំឃាំងទាំង ២៤ខេត្ត របស់ប្រទេសកម្ពុជា *(សូមមើលរូបភាពទី ២)*។

ការថយចុះនេះទទួលបានជោគជ័យដោយសាររាជរដ្ឋាភិបាលកម្ពុជា ជាមួយការគាំទ្រពីអង្គការ UNICEF អង្គការជំនួយផ្នែកច្បាប់កម្ពុជា(Legal Aid of Cambodia) អង្គការសិទ្ធិកុមារអន្តរជាតិ (Children's Rights International) និង អង្គការក្រៅរដ្ឋាភិបាលដទៃទៀត។ សកម្មភាពការងារអន្តរាគមន៍នៅក្នុងពេលនោះបានធ្វើឡើងនៅក្នុងរាជធានីខេត្តអាទិភាពប្រាំដែលរួមមាន ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល និង រាជធានីភ្នំពេញ ដែលជាកន្លែងមានទូរលេខអនីតិជនជាប់ឃុំច្រើនជាងគេ។

សកម្មភាពការងារមួយចំនួនដែលនាំឲ្យមានការថយចុះនេះរួមមាន ទីមួយ នៅដើមឆ្នាំ ២០១០ មានការកសាងសមត្ថភាពចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ទាក់ទងនឹងយន្តការយុត្តិធម៌កុមារមេត្រីដែលសមស្របទៅនឹងបទដ្ឋានអន្តរជាតិ។ ការងារភាពជាដៃគូរវាងអង្គការជំនួយផ្នែកច្បាប់កម្ពុជា(Legal Aid of Cambodia) និងអង្គការសិទ្ធិកុមារអន្តរជាតិ (Children's Rights International)ក៏បានចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននេះផងដែរ ដោយមន្ត្រីពាក់ព័ន្ធមួយចំនួនបានទទួលការបណ្តុះបណ្តាលស្តីពីនីតិវិធីកុមារមេត្រីនៅឯរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ការចុះត្រួតពិនិត្យតាមដាននៅតាមបណ្តាលខេត្តគោលដៅដែលបានធ្វើឡើងដោយមហាអយ្យការអបសាលាឧទ្ធរណ៍សហការជាមួយអង្គការUNICEF ដើម្បីធានាឲ្យមានការអនុវត្តនិតិវិធីកុមារមេត្រី ក៏ជាកត្តារុញច្រានឲ្យមានការផ្លាស់ប្តូរនេះដែរ។

ក្រៅពីនេះ ការបន្ធូបន្ថយទោសដល់អនីតិជនតាមរយៈព្រះរាជសារលើកលែងទោសពីព្រះមហាក្សត្របីដងក្នុង១ឆ្នាំ ដែលសម្របសម្រួលដោយក្រសួងយុត្តិធម៌ ក៏ជាកត្តារួមផ្សំមួយដែរ។

លើសពីនេះទៀត មានកម្មវិធីកិច្ចសហប្រតិបត្តិការ ការបណ្តុះបណ្តាល និងការពិនិត្យតាមដាន ដែលត្រូវបានធ្វើឡើងដោយអង្គការអន្តរជាតិ និងអង្គការក្នុងស្រុកនៅតាមតំបន់គោលដៅ ក៏ចូលរួមចំណែកក្នុងការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំនេះដែរ។ អង្គការជំនួយផ្នែកច្បាប់កម្ពុជា បានអនុវត្តកម្មវិធីបង្វែរក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងព្រៃវែង ដោយផ្អែកលើបណ្តាញយុវជនស្វែងរកការគាំទ្រតាមសហគមន៍។ ក្រៅពីក្មេងជំទង់ ក៏មាននគរបាលឃុំ និងមេឃុំបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ដើម្បីយល់ដឹងអំពីច្បាប់ និងអនុសញ្ញាជាធរមានផងដែរ។ ក្មេងជំទង់ៗក៏បានរៀនសូត្រអំពីរបៀបបង្ការពួកគេពីការទទួលរងទណ្ឌកម្មផងដែរ។ កម្មវិធីនេះមានគោលបំណងអនុវត្តកម្មវិធីបង្វែរក្រៅផ្លូវការមួយ តាមរយៈការទប់ស្កាត់ និងការប្រាស្រ័យទាក់ទងដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាននៅក្នុងសហគមន៍ នៅពេលមានអនីតិជនប្រឈមមុខនឹងបទល្មើស។ ជាលទ្ធផល គេសង្កេតឃើញមានការថយចុះនូវចំនួនសំណុំរឿងដែលផ្តឹងមកនគរបាល និងមានការថយចុះចំនួនអនីតិជនដែលជាប់ឃុំផងដែរ។ ពីថ្នាក់ស្រុករហូតដល់ថ្នាក់ឃុំ គម្រោងរបស់អង្គការជំនួយផ្នែកច្បាប់កម្ពុជាធ្វើការលើការបង្វែរ ជំនួយផ្នែកច្បាប់ និងការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធ។

ក្នុងខេត្តសៀមរាប កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ត្រូវបានបង្កើតឡើងរវាងអង្គការកល្យាណមិត្ត និងប៉ុស្តិ៍នគរបាលចំនួន ១៣។ មន្ត្រីនគរបាលបានទទួលការបណ្តុះបណ្តាលអំពីអនុសញ្ញាអន្តរជាតិ និងវិធាននានា ព្រមទាំងវិធានការផ្សេងក្រៅពីការដាក់ទណ្ឌកម្ម។ នៅគ្រប់ប៉ុស្តិ៍នគរបាលទាំងអស់ មានមន្ត្រីនគរបាលពិសេសម្នាក់ជាជនបង្គោលសម្រាប់បញ្ហាអនីតិជនទំនាស់នឹងច្បាប់ ដែលជាអ្នកធ្វើសេចក្តីរាយការណ៍អំពីហេតុការណ៍ទាំងអស់ដែលបានកើតឡើងទៅអង្គការកល្យាណមិត្ត។ ជំនួសឱ្យការបញ្ជូនទៅតុលាការ ជនល្មើសជាអនីតិជនត្រូវបានបញ្ជូនទៅមណ្ឌលសំចតរបស់អង្គការកល្យាណមិត្ត ដែលនៅទីនោះពួកគេទទួលបានការប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ បន្ទាប់មកពួកគេត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍របស់ខ្លួនវិញ ដោយមានបុគ្គលិកសង្គមកិច្ចជាអ្នកបន្តតាមដាន។ គម្រោងនេះត្រូវបានចាប់ផ្តើមនៅឆ្នាំ២០១៣ហើយបញ្ចប់ទៅវិញនៅឆ្នាំ២០១៦ដោយសារតែខ្វះជំនួយថវិកា។

នៅក្នុងរាជធានីខេត្តគោលដៅទាំងប្រាំ អង្គការ UNICEF បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងសំណុំរឿងអនីតិជនក្នុងពន្ធនាគារ ដោយ

ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើអនីតិជនកំពុងរង់ចាំការជំនុំជម្រះ ព្រមទាំងអនីតិជនដែលកំពុងរង់ចាំការដោះលែងក្នុងរយៈពេល ៦ ខែបន្ទាប់។

អនីតិជនកំពុងរង់ចាំការជំនុំជម្រះដែលពុំទាន់មានមេធាវី បានទទួលមេធាវី។ កាលណាអនីតិជនបានទទួលជំនួយផ្នែកច្បាប់កាន់តែល្អ អនីតិជនមានឱកាសកាន់តែច្រើនក្នុងការបង្វែរចេញពីប្រព័ន្ធតុលាការ។ អង្គការលីកាដូបានសង្កត់ធ្ងន់ថា ជនជាប់ឃុំបណ្តោះអាសន្នមុនការជំនុំជម្រះ ជារឿយៗតែងត្រូវជាប់ឃុំលើសរយៈពេលកំណត់ដែលមានចែងក្នុងច្បាប់ ដោយសារតែខ្វះមេធាវី។ បើទោះជាដូច្នេះក្តី ទស្សនកិច្ចពិនិត្យតាមដានពន្ធនាគារជាទៀងទាត់ ដែលបានធ្វើឡើងដោយអង្គការលីកាដូ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) ក្នុងគោលបំណងពង្រឹងច្បាប់ស្តីពីពន្ធនាគារ ក៏បាននាំឱ្យមានការថយចុះនូវចំនួនអនីតិជនជាប់ឃុំផងដែរ។ OHCHR ធ្លាប់បានអន្តរាគមន៍តាមករណីជាក់ស្តែងចំពោះសំណុំរឿងដែលហួសរយៈពេលកំណត់។

អនីតិជនកំពុងរង់ចាំការដោះលែងក្នុងរយៈពេល ៦ ខែបន្ទាប់ អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ដែលវិធានការបែបនេះអាចរួមចំណែកដល់ការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំផងដែរ។ ប្រសិនបើគ្មានការគ្រប់គ្រងសំណុំរឿង និងវត្តមានមេធាវី អនីតិជននឹងបន្តស្ថិតនៅក្នុងពន្ធនាគារហួសកាលកំណត់។

កាលពីឆ្នាំ២០១០ អង្គការICRC បានធ្វើការអង្កេតមួយទៅលើស្ថានភាពផ្ទុកអ្នកទោសហួសចំណុះក្នុង ពន្ធនាគារ។ បន្ទាប់ពីផ្សព្វផ្សាយលទ្ធផលអង្កេតរួចហើយ អង្គការនេះបានរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ឆ្នាំជាមួយរដ្ឋាភិបាល ដើម្បីកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ។

បន្ថែមពីលើនេះទៀត កិច្ចប្រជុំសម្របសម្រួលរវាងនគរបាល តុលាការ និងពន្ធនាគារ ត្រូវបានធ្វើឡើងជារៀងរាល់ត្រីមាសដោយមានការចូលរួមពីនគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី បុគ្គលិកសង្គមកិច្ច និងអង្គការពាក់ព័ន្ធមួយចំនួនដើម្បីពិភាក្សាអំពីបញ្ហាអនីតិជនទំនាស់នឹងច្បាប់ និងការបង្វែរពួកគេចេញពីប្រព័ន្ធតុលាការ ទៅរកជំរើសផ្សេងពីនេះ មានដូចជាវិធានការការងារតាមសហគមន៍ ឬតាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាដើម។

សកម្មភាពទាំងអស់នេះ ក៏ដូចជាទស្សនកិច្ចសិក្សាជាន់ខ្ពស់ ក្រោមការគាំទ្រពីអង្គការUNICEF ដែលបានធ្វើឡើងដើម្បីរៀនសូត្របទពិសោធន៍និងវិធីសាស្រ្តល្អៗទាក់ទងនឹងយុត្តិធម៌អនីតិជនពីប្រទេសអូស្រ្តាលី និងប្រទេសញ៉ូហ្សីលែននោះ  បានបង្កើនការយល់ដឹងដល់មន្ត្រីរដ្ឋាភិបាលសំខាន់ៗ និងបង្កើនការគាំទ្រឱ្យមានការបង្វែរ ដែលជាហេតុនាំឱ្យមានការថយចុះនូវចំនួនអនីតិជនជាប់ពន្ធនាគារ។

ថ្វីបើមានភាពប្រសើរឡើងក្នុងប្រព័ន្ធយុត្តិធម៌ និងមានកិច្ចខិតខំដើម្បីលើកកម្ពស់ជម្រើសផ្សេងក្រៅពីការឃុំខ្លួនក្តី ថ្មីៗនេះ ចំនួនអនីតិជនជាប់ឃុំមានការកើនឡើងជាថ្មី។ យោងតាមរបាយការណ៍របស់អង្គការ HAGAR ចុះខែមករា ឆ្នាំ២០១៥ ដែលមានចំណងជើងថា "ប្រព័ន្ធមួយសម្រាប់តែអនីតិជន" បានឱ្យដឹងថា ការអនុវត្តនីតិវិធីកុមារមេត្រីនៅមានកម្រិតនៅឡើយ។

## តើហេតុអ្វីបានជាថ្មីៗនេះមានការកើនឡើងនូវចំនួនអនីតិជនជាប់ឃុំ?

ផ្អែកលើទិន្នន័យរបស់ក្រសួងមហាផ្ទៃ បានឱ្យដឹងថា ចំនួនជនល្មើសជាអនីតិជនបានកើនឡើងពី ២,៩% ក្នុងឆ្នាំ ២០១៥ ដល់ ៤% នៃចំនួនអ្នកជាប់ពន្ធនាគារសរុបដោយគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៧ ដោយក្នុងនោះ រួមមានអនីតិជនចំនួន៩០៧នាក់[6]ដែលជាប់ឃុំក្នុងខេត្តទាំង ២៤។ បើគិតពីឆ្នាំ២០១៥មក អនីតិជនជាប់ឃុំមានការកើនឡើងរហូតដល់៨០% និង ១៧០%បើគិតពីឆ្នាំ២០១៤។

ឯកឧត្តម កង សខន អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា បានពន្យល់ប្រាប់ថា ការកើនឡើងនេះ មានហេតុផល ៣ សំខាន់ៗគឺ៖ ទី១ ការកើនឡើងនៃបទល្មើសទាក់ទងជាមួយសកម្មភាពគ្រឿងញៀន ទី២ កង្វះការថែទាំ ឬការមើលខុសត្រូវឲ្យបានល្អពីឪពុកម្តាយដែលបានចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅខេត្តដទៃឬក្រៅប្រទេស ដោយផ្ញើកូននៅជាមួយសាច់ញាតិ ជាហេតុធ្វើឱ្យមានភាពងាយរងគ្រោះកាន់តែខ្លាំង និងងាយនឹងប្រព្រឹត្តបទល្មើស និងទី៣ គឺអនីតិជនដែលផ្លាស់លំនៅពីតាមបណ្តាខេត្តមកនៅទីក្រុង ដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយសារគ្រឿងញៀន និងបទល្មើស។ ឯកឧត្តម កង សខនបានគូសបញ្ជាក់ថា អនីតិជនអាចជាអ្នកប្រព្រឹត្តបទល្មើស និងជាជនរងគ្រោះផងដែរ។

ផ្អែកលើទិន្នន័យថ្មីៗនេះ និងយោងតាមអ្នកជំនាញជាមន្ត្រីរាជរដ្ឋាភិបាល ព្រមទាំងអ្នកជំនាញកិច្ចការពារកុមារ គឺមានកត្តាសំខាន់ៗចំនួន ៥ ដែលបង្កឲ្យមានការកើនឡើងអនីតិជនជាប់ឃុំនេះ ហើយដែលកត្តាទាំង៥នេះមានពន្យល់ជូនខាងក្រោម។

### គ្រឿងញៀន

ហេតុផលចម្បងមួយនៃកំណើនអនីតិជនជាប់ឃុំ គឺការចាប់ខ្លួនរបស់ពួកគេនៅក្នុងកំឡុងពេលនៃការអនុវត្តវិធានការតឹងរឹងលើការប្រើប្រាស់គ្រឿងញៀនរបស់រាជរដ្ឋាភិបាល។ មានការកើនឡើងនៃចំនួនក្មេងជំទង់ដែលចូលរួមសកម្មភាពគ្រឿងញៀន (ប្រើប្រាស់ លក់ និងការជួញដូរ)។ គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺត្រូវបញ្ជូនអ្នកប្រើប្រាស់គ្រឿងញៀនទៅក្នុងមណ្ឌលស្តារនីតិសម្បទា ចំណែកឯអ្នកពាក់ព័ន្ធក្នុងសកម្មភាពគ្រឿងញៀនធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅមណ្ឌលកែប្រែទី២សម្រាប់អនីតិជន(មព២)។ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃបានអះអាងថា យុទ្ធនាការណ៍កម្ចាត់គ្រឿងញៀនរបស់រាជរដ្ឋាភិបាល បានធ្វើឱ្យមានការកើនឡើងនូវចំនួនអ្នកជាប់ឃុំគួរឲ្យកត់សម្គាល់ ដែលក្នុងនោះរាប់បញ្ចូលទាំងអនីតិជនផងដែរ។

យោងតាមប្រសាសន៍របស់លោកប្រធានសាលាដំបូងខេត្តសៀមរាបបានឲ្យដឹងថានៅឆ្នាំ២០១៦ ក្នុងចំណោមអនីតិជនជាប់ចោទចំនួន២៣៦នាក់ មាន១៥២ករណីទាក់ទងនឹងបទល្មើសគ្រឿងញៀន។ ហើយនៅឆ្នាំ២០១៧ ក្នុងចំណោមអនីតិជនជាប់ចោទចំនួន១១៣នាក់ មាន៩២ករណីជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

[6] Ministry of Interior, General Department of Prisons, January 2017.

## កង្វះធនធាន

បើទោះបីជាការបង្វែរមានចែងក្នុងក្រមព្រហ្មទណ្ឌក៏ដោយ ក៏មន្ត្រីតុលាការនិងមន្ត្រីសង្គមកិច្ចបានបញ្ជាក់ពីកង្វះខាតនៃយន្តការនិងធនធានដើម្បីអនុវត្តវិធានការផ្សេងក្រៅពីការដាក់ឃុំ ហើយដែលកង្វះខាតនេះរួមមានទាំងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស។

កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ក្រសួងយុត្តិធម៌បានចេញសារាចរចំនួនបី៖ សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការព្យួរទោសសាកល្បង និងសារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការអនុវត្តទោសការងារសហគមន៍។ សារាចរទាំងបីនេះគឺស្ថិតនៅថ្នាក់ជាតិនៅឡើយ ដោយសារពុំទាន់មានយន្តការសម្រាប់អនុវត្តនៅថ្នាក់ក្រោមជាតិនៅឡើយ។ ចាប់តាំងពីពេលនោះមក អង្គការ *ICRC* ក៏បានបញ្ឈប់កិច្ចប្រជុំជាទៀងទាត់ជាមួយរដ្ឋាភិបាល។

ក្រៅពីនេះ ដោយសារតែនៅពេលនោះមានការថយចុះចំនួនអនីតិជនក្នុងពន្ធនាគារ និងមានដំណើរការទៅមុខនៃការតាក់តែងច្បាប់ថ្មីស្តីពីយុត្តិធម៌អនីតិជននោះ ដៃគូអភិវឌ្ឍដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននិង *UNICEF* បានងាកទៅរកការងារផ្នែកកិច្ចការពារកុមារផ្សេងវិញ។

ដោយសារតែកង្វះធនធាន ធ្វើឲ្យកម្មវិធីបង្វែរជាច្រើន កម្មវិធីការកសាងសមត្ថភាព និងគម្រោងបណ្តុះបណ្តាលត្រូវបានបញ្ឈប់។ ជាលទ្ធផលធ្វើឲ្យចៅក្រមថ្មីៗ ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីនគរបាលពុំទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីយុត្តិធម៌អនីតិជនដែលជាហេតុធ្វើឲ្យការយល់ដឹងនិងជំនាញរបស់ពួកគេលើរឿងនេះនៅមានកម្រិត។

## ការថយចុះជំនួយផ្នែកយុត្តិធម៌

ក្រៅពីកត្តាខាងលើ ជំនួយផ្នែកយុត្តិធម៌សម្រាប់អនីតិជនទំនាស់នឹងច្បាប់ក៏បានថយចុះផងដែរ។ ចាប់ពីឆ្នាំ២០០៦មក មានគម្រោងរបស់អង្គការអន្តរជាតិមួយចំនួនដែលបានធ្វើអន្តរាគមន៍ក្នុងប្រទេសកម្ពុជា ដើម្បីជួយឆ្លើយតបចំពោះស្ថានភាពលំបាកក្នុងពន្ធនាគារ ដូចជាភាពចង្អៀត លក្ខខណ្ឌមិនល្អ កង្វះអាហារ កង្វះការព្យាបាល។ល។ ដែលធ្វើឲ្យស្ថានភាពបានល្អប្រសើរយ៉ាងឆាប់រហ័ស។ ចាប់ពីឆ្នាំ ២០១៥ មក ទស្សនកិច្ចនៅក្នុងពន្ធនាគារជាទៀងទាត់ដែលធ្វើឡើងដោយមន្ទីរសង្គមកិច្ចខេត្ត បានថយចុះដោយសារកង្វះធនធាន។ លើសពីនេះទៀត អង្គការ *LICADHO* និង *OHCHR* ក៏មានបញ្ហាក្នុងការចូលពិនិត្យក្នុងពន្ធនាគារផងដែរ ដោយចាប់តាំងពីឆ្នាំ២០១៦មក *OHCHR* មិនត្រូវបានអនុញ្ញាតឲ្យចូលសំភាសន៍អ្នកទោសក្នុងពន្ធនាគារទៀតឡើយបើពុំមានវត្តមានបុគ្គលិកពន្ធនាគារទេ ដែលការណ៍នេះធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃចម្លើយដែលទទួលបានពីការសំភាសន៍។

ក្រៅពីនេះ ចាប់តាំងពីឆ្នាំ២០១៦មក កិច្ចសហការជាទៀងទាត់រវាងមន្ត្រីពន្ធនាគារនិងមន្ត្រីតុលាការក៏បានថយចុះ ហើយការអនុវត្តវិធានការផ្សេងក្រៅពីការឃុំខ្លួនដែលត្រូវបានលើកដង្កើននៅឆ្នាំ២០១០ ដែលមានដូចជាការអប់រំក៏បានថយចុះផងដែរ។

### កង្វះការយល់ដឹងនៅតាមសហគមន៍

សាធារណជនទូទៅមានភាពស្ទាក់ស្ទើរក្នុងការដោះលែង ឬ បង្វែរជនល្មើសដែលត្រូវបានសាលក្រមប្រកាសឱ្យជាប់ទោស។ ប្រធានសាលាដំបូងខេត្តសៀមរាបបានគូសបញ្ជាក់នៅក្នុងកិច្ចប្រជុំជាមួយមន្ត្រី *UNICEF*កាលពីខែឧសភាឆ្នាំ ២០១៧ថា ជម្រើសផ្សេងក្រៅពីការឃុំខ្លួនសម្រាប់បទល្មើសមជ្ឈិមនិងបទឧក្រិដ្ឋមានការពិបាកក្នុងការអនុវត្ត ដោយសារប្រជាពលរដ្ឋនៅតាមសហគមន៍ពុំទាន់មានការយល់ដឹងអំពីសិទ្ធិអនីតិជននិងច្បាប់យុត្តិធម៌អនីតិជននៅឡើយ។

មានការយល់ឃើញធម្មតាមួយថា ការបង្វែរជនល្មើសចេញពីប្រព័ន្ធតុលាការ អាចបង្កើន ឬលើកទឹកចិត្តការប្រព្រឹត្តបទល្មើស ដោយសារទុកឱ្យជនល្មើសមានសេរីភាពនិងមិនដាក់ទោសដល់ពួកគេ។ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក អ៊ុប វិបុល មេធាវីរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា យល់ស្របថា បញ្ហាប្រឈមចម្បងមួយគឺការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋកម្ពុជា និងសហគមន៍ ឲ្យយល់ដឹងអំពីការបង្វែរ តាមរយៈការផ្តល់ការអប់រំ និងការបណ្តុះបណ្តាល។

### អវត្តមានលិខិតបញ្ជាក់កំណើត

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារ មានក្តីបារម្ភអំពីអត្រាដ៏ទាបនៃការចុះបញ្ជីកំណើត។ ជាលទ្ធផល ក្នុងករណីភាគច្រើននៃការចាប់ខ្លួនអនីតិជន ការកំណត់អាយុគឺធ្វើឡើងដោយមិនច្បាស់លាស់ ហើយផ្អែកលើការពិនិត្យមើលរូបរាងកាយខាងក្រៅ។ កង្វះលិខិតបញ្ជាក់កំណើត គឺជាកង្វល់ដ៏ចម្បងមួយសម្រាប់មន្ត្រីពាក់ព័ន្ធក្នុងការបញ្ជាក់អាយុរបស់ជនល្មើសវ័យក្មេង ដោយហេតុថាអនីតិជនក្រោមអាយុ១៤ឆ្នាំ មិនអាចត្រូវបានចាប់ខ្លួន និងចោទប្រកាន់ផ្តន្ទាទោសឡើយ ពីព្រោះថាយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងករណីមានការសង្ស័យអំពីអាយុអនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ទៅអនីតិជននោះ[7]។

ផ្អែកលើការវិភាគនេះ គេអាចកំណត់ផែនការសកម្មភាពមួយចំនួនសម្រាប់អនុវត្ត ដើម្បីធ្វើការបង្វែរ និងនាំឱ្យមានការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ។ ផ្នែកបន្ទាប់នេះមានគោលបំណងគូសបញ្ជាក់អំពីកត្តាជម្រុញ និង ឧបសគ្គមួយចំនួនដែលជួយសម្របសម្រួល និង បង្កឱ្យមានផលប៉ះពាល់ដល់ការអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយផ្អែកលើការសិក្សារបស់អង្គការ UNICEF។

## កត្តាជម្រុញ និងឧបសគ្គក្នុងការអនុវត្តកម្មវិធីបង្វែរ ចំពោះករណីអនីតិជនទំនាស់នឹងច្បាប់[8]

លទ្ធផលនៃការសិក្សាថ្នាក់តំបន់មួយដែលនិយាយពីការបង្វែរ និងវិធានការផ្សេងក្រៅពីការឃុំខ្លួនអនីតិជនទំនាស់នឹងច្បាប់ ដែលបានធ្វើឡើងក្នុងតំបន់អាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក ដោយអង្គការ UNICEFថ្នាក់តំបន់ បានគូសបញ្ជាក់

[7] Handley, Erin, 'New law 'urgent', but imperfect', *The Phnom Penh Post*, 26 December 2016
[8] United Nations Children's Fund, *'Diversion not Detention: A study on diversion and other alternative measures for children in conflict with the law in East Asia and the Pacific'*, UNICEF EAPRO, 2017

អំពីកត្តាជម្រុញ និងឧសគ្គចម្បងៗក្នុងការអនុវត្តកម្មវិធីបង្វែរករណីអនីតិជនទំនាស់នឹងច្បាប់ និងផ្តល់ជាអនុសាសន៍សំខាន់ៗមួយចំនួន។

**កត្តាជម្រុញសំខាន់ៗ និងកត្តាជោគជ័យរួមមាន៖**

- បទប្បញ្ញត្តិច្បាប់ជាក់លាក់សម្រាប់អនីតិជនដែលចែងអំពីការបង្វែរ ជម្រើសផ្សេងក្រៅពីការឃុំខ្លួនមុន និងក្រោយពេលជំនុំជម្រះ និងអភិក្រមយុត្តិធម៌ស្តារនីតិសម្បទាឡើងវិញ រួមជាមួយនឹងគោលការណ៍ណែនាំនិងនិតិវិធីប្រតិបត្តិការស្តង់ដារដើម្បីចង្អុលបង្ហាញពីការអនុវត្តកម្មវិធីបង្វែរនិងជម្រើសផ្សេងក្រៅពីការឃុំខ្លួន។
- យន្តការសម្របសម្រួល យន្តការអនុវត្ត និងយន្តការពិនិត្យតាមដានការបង្វែរនិងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួន។
- ការផ្សព្វផ្សាយ ការយល់ដឹង ការប្តេជ្ញាចិត្ត និងការកសាងសមត្ថភាពរបស់អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌អនីតិជន និងភាគីពាក់ព័ន្ធនានាដែលចូលរួមក្នុងការអនុវត្តកម្មវិធីបង្វែរ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួន។
- ការទទួលយកការបង្វែរ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួន ពីសំណាក់សាធារណជនទូទៅ ឪពុកម្តាយអាណាព្យាបាល និងសហគមន៍។
- ធនធានមនុស្សគ្រប់គ្រាន់ ជាពិសេសបុគ្គលិកសង្គមកិច្ច និងអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌អនីតិជន និង/ឬ អ្នកស្ម័គ្រចិត្ត។
- សេវាការងារសហគមន៍ជាក់លាក់និងកម្មវិធីផ្សេងៗសម្រាប់ឲ្យអនីតិជនទំនាស់នឹងច្បាប់អនុវត្ត។
- មានជម្រើសផ្សេងៗជំនួសឱ្យការឃុំខ្លួនក្រោយពេលជំនុំជម្រះដែលមានចែងនៅក្នុងច្បាប់ជាតិ និងត្រូវបានប្រតិបត្តិនៅក្នុងការអនុវត្តជាក់ស្តែង ដើម្បីឱ្យជម្រើសទាំងនោះត្រូវបានផ្តល់ជូនស្របតាមតម្រូវការ និងកាលៈទេសៈរបស់អនីតិជនទំនាស់នឹងច្បាប់។
- បុព្វហេតុឫសគល់នៃអាកប្បកិរិយាប្រព្រឹត្តបទល្មើសរបស់អនីតិជន ត្រូវបានដោះស្រាយតាមរយៈការរៀបចំផែនការ បង្វែរ/ធ្វើសមាសហរណកម្មអនីតិជន/កិច្ចសន្យា។
- ការប្រើប្រាស់របាយការណ៍មានគុណភាពស្តីពីការប៉ាន់ប្រម៉ានសុខមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជនប្រព្រឹត្តបទល្មើសដែលធ្វើឡើងដោយមន្ត្រីសង្គមកិច្ច ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តលើវិធានការផ្សេងៗក្រៅពីការឃុំខ្លួន។
- ការត្រួតពិនិត្យឡើងវិញជាប្រចាំលើការឃុំខ្លួន មុននិងក្រោយការជំនុំជម្រះ ដើម្បីកាត់បន្ថយពេលវេលាដែលអនីតិជនត្រូវបានដកហូតសេរីភាព។

**ឧបសគ្គ និងបញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្តកម្មវិធីបង្វែរ រួមមាន៖**

- កង្វះក្របខណ្ឌការងារផ្នែកច្បាប់ជាក់លាក់ស្ដីពីអនីតិជន និតិវិធីប្រតិបត្តិការស្តង់ដារស្ដីពីការបង្វែរ និងវិធានផ្សេងទៀតក្រៅពីការឃុំខ្លួន។
- ខ្វះការផ្សព្វផ្សាយ ការយល់ដឹង និងការប្តេជ្ញាចិត្តពីអាជ្ញាធរមូលដ្ឋាន និង/ឬ អ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌អនីតិជន ដែលចូលរួមក្នុងការអនុវត្តការបង្វែរ និងវិធានផ្សេងទៀតក្រៅពីការឃុំខ្លួន។
- កង្វះធនធានមនុស្ស។
- កង្វះការគាំទ្រពីសាធារណជនទូទៅ សហគមន៍ ឪពុកម្ដាយ/ អាណាព្យាបាល និង/ ឬជនរងគ្រោះ លើការបង្វែរ និងវិធានផ្សេងទៀតក្រៅពីការឃុំខ្លួន ដោយពួកគេនៅតែយល់ថាអ្នកប្រព្រឹត្តបទល្មើសគួរទទួលទោស។
- កង្វះអង្គការធ្វើការតាមសហគមន៍ សេវា និងជម្រើសនានាសម្រាប់អនីតិជនទំនាស់នឹងច្បាប់ជ្រើសរើស។
- កង្វះជំនួយផ្នែកច្បាប់សម្រាប់អនីតិជនទំនាស់នឹងច្បាប់ នៅក្នុងដំណើរការនីតិវិធីតុលាការទាំងមូល។
- របាយការណ៍ស្ដីពីការប៉ាន់ប្រម៉ានសុខមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជនប្រព្រឹត្តបទល្មើសដែលធ្វើឡើងដោយមន្ត្រីសង្គមកិច្ច ពុំទាន់មានគុណភាពពេញលេញដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចចិត្តលើជម្រើសផ្សេងក្រៅពីការឃុំខ្លួន។
- បុព្វហេតុឫសគល់នៃអាកប្បកិរិយាប្រព្រឹត្តបទល្មើសរបស់អនីតិជន មិនត្រូវបានដោះស្រាយតាមរយៈការរៀបចំផែនការបង្វែរ/ធ្វើសមាសហរណកម្មអនីតិជន/កិច្ចសន្យា។
- ការដាក់អនីតិជននៅក្នុងមណ្ឌលទទួលស្នាក់នៅពេលថ្ងៃនិងមណ្ឌលទទួលស្នាក់នៅទាំងថ្ងៃនិងយប់ ត្រូវបានចាត់ទុកថាជាវិធានការផ្សេងជំនួសឲ្យការឃុំខ្លួន។
- ពុំមានការត្រួតពិនិត្យឡើងវិញជាប្រចាំ លើការឃុំខ្លួនមុននិងក្រោយពេលជំនុំជម្រះ។
- ពុំមានស្ថិតិពេញលេញនិងបែងចែកទៅតាមប្រភេទ ស្ដីអំពីវិធានការផ្សេងក្រៅពីការឃុំខ្លួន។

## ផែនការសកម្មភាពជាមូលដ្ឋាន

ផ្អែកលើការវិភាគ និងអនុសាសន៍ខាងដើម ផ្នែកនេះគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗដើម្បីឈានទៅរកការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ។

## លទ្ធផលរយៈពេលវែង ៖ កាត់បន្ថយឱ្យបាន ៥០% ចំពោះចំនួនកុមារជាប់ឃុំ ត្រឹមឆ្នាំ២០១៨

### <u>លទ្ធផលរយៈពេលខ្លីទី១ ៖ ប្រព័ន្ធយុត្តិធម៌អនីតិជនក្នុងសហគមន៍ប្រកបដោយប្រសិទ្ធិភាពមួយត្រូវបានបង្កើតឡើង</u>

| សេចក្ដីពណ៌នាដែលបានគ្រោងទុក | ក្របខ័ណ្ឌពេលវេលា ២០១៨ | | | | ក្របខ័ណ្ឌពេលវេលា ២០១៩ | | | | ដៃគូអនុវត្ត | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | |
| 1.1. អនុវត្តកម្មវិធីបង្វែរ ដោយផ្អែកលើបណ្ដាញស្វែងរកការគាំទ្ររបស់យុវជនក្នុងសហគមន៍ ដើម្បីកាត់បន្ថយចំនួនករណីដែលបានរាយការណ៍ទៅនគរបាល។ | | X | X | X | X | X | X | X | មន្ទីសង្គមកិច្ច<br>អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br>អង្គការ Plan International<br>អង្គការ Friends International និង<br>អង្គការយូនីសេហ្វ។ | បង្ការ ទំនាក់ទំនង សន្ទានកម្ម។ |
| 1.1.1. ផ្ដល់ដល់សមាជិកសហគមន៍ (រាប់បញ្ចូលមេភូមិ នគរបាលឃុំ គ្រូបង្រៀន/នាយកសាលា កុមារ ក្មេងជំទង់ គ្រួសារ) នូវចំណេះដឹងអំពីសិទ្ធិកុមារ និង ការយល់ដឹងអំពីគុណសម្បត្តិនៃការបង្វែរ និង គុណវិបត្តិនៃការឃុំខ្លួន។ | | X | X | X | X | X | X | X | មន្ទីសង្គមកិច្ច<br>អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br>អង្គការ Plan International<br>អង្គការ Friends International និង<br>អង្គការយូនីសេហ្វ។ | |
| 1.1.2. បណ្ដុះបណ្ដាលសមាជិកសហគមន៍ និង ប្រធានសហគមន៍ អំពីការបង្វែរក្រៅប្រព័ន្ធតុលាការ និង ដំណោះ ស្រាយផ្សេងក្រៅពីការដាក់ទណ្ឌកម្មតាមរយៈការបង្ការ និង ការប្រាស្រ័យទាក់ទង។ | | X | X | X | X | X | X | X | មន្ទីសង្គមកិច្ច<br>អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br>អង្គការ Plan International<br>អង្គការ Friends International និង<br>អង្គការយូនីសេហ្វ។ | |
| 1.1.3. កម្មវិធីតាមដាន និងត្រួតពិនិត្យ។ | | | X | X | X | X | X | X | មន្ទីសង្គមកិច្ច<br>អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br>អង្គការ Plan International<br>អង្គការ Friends International និង<br>អង្គការយូនីសេហ្វ។ | |
| 1.2. បង្កើតអង្គភាពសន្ទានកម្មកុមារថ្នាក់ភូមិ ដើម្បីសម្របសម្រួលឱ្យមានកិច្ចសហការរវាងនគរបាល និង មេដឹកនាំសហគមន៍ដើម្បីដោះស្រាយករណីនៅកម្រិតសហគមន៍។ | | | | X | X | X | X | X | ក្រសួងយុត្តិធម៌/ក្រសួង សអយ | ដំណើរការសន្ទានកម្មដែលពាក់ព័ន្ធភាគីទាំងពីរ និងរាប់បញ្ចូលការសូមទោស ការផ្ដល់សំណង ការធ្វើការងារក្នុងសហគមន៍ និង ការអប់រំឡើងវិញ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 1.2.1. បង្កើត និងផ្សព្វផ្សាយអំពីការបង្វែរ និង គោលការណ៍ណែនាំស្តីពីសន្ទានកម្មកុមារ។ | | X | X | | | | | | ក្រសួងយុត្តិធម៌/ក្រសួង សអយ | |
| 1.2.2. បណ្តុះបណ្តាលមេដឹកនាំសហគមន៍ នគរបាល និង តួអង្គពាក់ព័ន្ធ (រាប់បញ្ចូលព្រះសង្ឃ) អំពីសន្ទានកម្មកុមារ។ | | | X | X | X | X | X | X | មន្ទីសង្គមកិច្ច | |
| 1.3. ពង្រឹងការកសាងសមត្ថភាពរបស់នគរបាលឃុំ និង កិច្ចសហការរវាងនគរបាលឃុំ និង អង្គការក្នុងមូលដ្ឋាន/សេវាសង្គម។ | X | X | X | X | X | X | X | X | អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួង សអយ និង អង្គការ Friends International។ | |
| 1.3.1. បណ្តុះបណ្តាលនគរបាលឃុំ/សង្កាត់អំពីបញ្ហាកិច្ចការពារកុមារ និង យន្តការកុមារមេត្រី និងតែងតាំងជនបង្គោលទទួលបន្ទុកការងារការពារកុមារនៅឯប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់។ | X | X | X | X | | | | | អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។ | |
| 1.3.2. បញ្ចូលច្បាប់ស្តីពីយុត្តិធម៌អនីតិជន និង បទប្បញ្ញត្តិបទដ្ឋានអន្តរជាតិ ទៅក្នុងកម្មវិធីសិក្សានៃបណ្ឌិតសភានគរបាលកម្ពុជា។ | | | | X | X | X | X | X | បណ្ឌិតសភានគរបាលកម្ពុជា | |
| 1.3.3. អនុវត្តការឆ្លើយតបក្រៅប្រព័ន្ធតុលាការតាមបែបផ្លូវការឬក្រៅផ្លូវការ ចំពោះបទល្មើស តាមរយៈវិធានការស្តារនីតិសម្បទាយុវជន និងការដោះលែងយុវជនឱ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ។ ពង្រឹងការប្រាស្រ័យទាក់ទងល្អ/កិច្ចសហការល្អនៅគ្រប់ជាន់ថ្នាក់នៃថ្នាក់ដឹកនាំ។ | | | X | X | X | X | X | X | អគ្គស្នងការដ្ឋាននគរបាលជាតិ | វិធានការស្តារនីតិសម្បទាយុវជន ៖ វិធានការបែបមិនផ្លូវការដែលនគរបាលប្រើប្រាស់ ដើម្បីលើកទឹកចិត្តឱ្យមានការសូមទោសចំពោះជនរងគ្រោះ និង/ឬ ចំណាត់ការស្តារនីតិសម្បទាដទៃទៀត ដោយមិនបង្កឱ្យមានកំណត់ហេតុព្រហ្មទណ្ឌ។<br>ការដោះលែងយុវជនឱ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ៖ វិធានការក្រៅប្រព័ន្ធតុលាការដែលគេប្រើប្រាស់ក្នុងលក្ខណៈជាជម្រើសផ្សេងក្រៅពីការផ្តន្ទាទោស។ |
| 1.3.4. បង្កើតមណ្ឌលសំចត សម្រាប់បញ្ជូនជនល្មើសជាអនីតិជនទៅទីនោះ ជំនួសឱ្យការបញ្ជូនពួកគេទៅតុលាការ ហើយ ផ្តល់ប្រឹក្សាយោបល់ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ | | | X | X | X | X | X | X | មន្ទីសង្គមកិច្ច និង អង្គការក្រៅរដ្ឋាភិបាល។ | |
| **<u>លទ្ធផលរយៈពេលខ្លីទី២ ៖ សមត្ថភាពរបស់តុលាការមានការកើនឡើង និង ចំនួនកុមារដែលត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារមានការថយចុះ</u>** | | | | | | | | | | |

| សេចក្តីពណ៌នាដែលបានគ្រោងទុក | ក្របខ័ណ្ឌពេលវេលា ២០១៨ | | | | ក្របខ័ណ្ឌពេលវេលា ២០១៩ | | | | ដៃគូអនុវត្ត | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | |
| 2.1. បង្កើតក្រុមការងារពហុវិស័យដែលមានឯកទេសផ្នែកការពារកុមារ ដើម្បីប៉ាន់ប្រមាណ និងស្វែងយល់អំពីសេចក្តីត្រូវការរបស់កុមារ និងផ្តល់យោបល់ដល់ចៅក្រមទាក់ទងការសម្រេចធ្វើការបង្វែរ។ | | X | X | X | X | X | X | X | ក្រសួង សអយ និង អង្គការយូនីសេហ្វ។ | ក្រុមការងារពហុវិស័យនេះផ្អែកលើគំរូរបស់ប្រទេសថៃ (ក្រុមការងារពហុវិស័យនៃមជ្ឈមណ្ឌលសង្កេត និងការពារអនីតិជន និង មជ្ឈមណ្ឌលផ្តល់ប្រឹក្សាយោបល់ នៃតុលាការអនីតិជន និងគ្រួសារ)។ |
| 2.1.1. ជ្រើសរើស និង បណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ច និងអ្នកឯកទេសរធ្វើការងារជាមួយកុមារទំនាស់នឹងច្បាប់ស្តីពីការអនុវត្តវិធានការបង្វែរ និង វិធានការផ្សេងក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន មុនពេល និងក្រោយពេលជំនុំជម្រះ។ | | X | X | X | | | | | ក្រសួង សអយ | |
| 2.1.2. ផ្សព្វផ្សាយដល់ឪពុកម្តាយ/អ្នកអាណាព្យាបាល/គ្រួសាររបស់កុមារឲ្យយល់ដឹងពីការចិញ្ចឹមកូនបែបវិជ្ជមាន អត្ថប្រយោជន៍នៃការបង្វែរ និងគុណវិបត្តនៃការឃុំកុមារ។ | | X | X | X | X | X | X | X | មន្ទីសង្គមកិច្ច | |
| 2.1.3. រៀបចំរបាយការណ៍អំពីការការប៉ាន់ប្រមាណសុខមាលភាពនិងស្ថានភាពសង្គមរបស់កុមារគ្រប់ករណីទាំងអស់។ | | X | X | X | X | X | X | X | មន្ទីសង្គមកិច្ច ក្រុមការងារពហុវិស័យ | យល់ដឹងអំពីសេចក្តីត្រូវការ និងការលើកទឹកចិត្តឲ្យមានសមាហរណកម្ម ការស្តារនីតិសម្បទា ការស្តារឡើងវិញ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួន។ |
| 2.2. បង្កើនការកសាងសមត្ថភាពរបស់របស់ចៅក្រម និង មន្ត្រីពាក់ព័ន្ធឯទៀតរបស់តុលាការ។ | X | X | X | X | X | X | X | X | ក្រសួងយុត្តិធម៌ អង្គការHagar និងអង្គការយូនីសេហ្វ។ | |
| 2.2.1. បង្កើត និង ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីនីតិវិធីនិងយន្តការកុមារមេត្រី។ | X | X | X | X | | | | | ក្រសួងយុត្តិធម៌និងអង្គការHAGAR | |
| 2.2.2. បណ្តុះបណ្តាលចៅក្រមអំពីនីតិវិធី និងយន្តការកុមារមេត្រី។ | | X | X | X | | | | | ក្រសួងយុត្តិធម៌និងអង្គការHAGAR | ការបណ្តុះបណ្តាលដែលផ្តល់ជូនក្រោមកិច្ចសហការជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ |
| 2.2.3. បញ្ចូលច្បាប់ស្តីពីយុត្តិធម៌អនីតិជន និង បទប្បញ្ញត្តិបទដ្ឋានអន្តរជាតិ ទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជិវៈតុលាការ។ | X | X | X | X | X | X | X | X | ក្រសួងយុត្តិធម៌/រាជបណ្ឌិតសភាវិជ្ជាជិវៈតុលាការ | |

| លទ្ធផលរយៈពេលខ្លីទី៣ ៖ ការគ្រប់គ្រងករណី និងជំនួយផ្នែកច្បាប់សម្រាប់កុមារក្នុងពន្ធនាគារ មានភាពប្រសើរឡើង | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សេចក្តីពណ៌នាដែលបានគ្រោងទុក | ក្របខ័ណ្ឌពេលវេលា ២០១៨ | | | | ក្របខ័ណ្ឌពេលវេលា ២០១៩ | | | | ដៃគូអនុវត្ត | សម្គាល់ |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | |
| 3.1. កែលម្អការគ្រប់គ្រងករណីរបស់អនីតិជននៅក្នុងពន្ធនាគារ។ | | X | X | X | X | X | X | X | មន្ទីរសង្គមកិច្ច អង្គការលីកាដូ អង្គការ ICRC អង្គការ OHCHR និង អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ | |
| 3.1.1. ចុះធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់នៅតាមពន្ធនាគារដើម្បីប៉ាន់ប្រមាណស្ថានភាពរបស់អនីតិជន។ | | X | X | X | X | X | X | X | មន្ទីរសង្គមកិច្ច អង្គការ ICRC អង្គការលីកាដូ និង អង្គការ OHCHR។ | |
| 3.1.2. ផ្តល់ជំនួយផ្នែកច្បាប់ជូនកុមារកំពុងរង់ចាំការជំនុំជម្រះ ដែលពុំមានមេធាវី។ | | X | X | X | X | X | X | X | មន្ទីរសង្គមកិច្ច អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា | |
| 3.1.3. សម្របសម្រួលឱ្យមានការដោះលែងក្រោមលក្ខខណ្ឌ ចំពោះអ្នកជាប់ឃុំបណ្តោះអាសន្នមុនពេលជំនុំជម្រះ និង អ្នកជាប់ឃុំដែលរង់ចាំការដោះលែងក្នុងរយៈពេល៦ខែបន្ទាប់។ | | X | X | X | X | X | X | X | មន្ទីរសង្គមកិច្ច និង អង្គការលីកាដូ។ | |
| 3.2. កែលម្អការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្មជនល្មើសជាអនីតិជន | | X | X | X | X | X | X | X | មន្ទីរសង្គមកិច្ច | |
| 3.2.1. បញ្ជូនអនីតិជនដែលត្រូវបានផ្តន្ទាទោស ទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានលក្ខណៈកុមារមេត្រី ដើម្បីត្រៀមលក្ខណៈពួកគេសម្រាប់ធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។ | | | X | X | X | X | X | X | មន្ទីរសង្គមកិច្ច | |
| 3.2.2. ផ្តល់ជំនួយពិសេសសម្រាប់ជនល្មើសគ្រឿងញៀន (ការបន្សាប ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ)។ | | | X | X | X | X | X | X | មន្ទីរសង្គមកិច្ច | |
| 3.2.3. គាំទ្រ និងតាមដានការងារសមាហរណកម្មអនីតិជននៅក្នុងសហគមន៍របស់ពួកគេ ក្រោយពេលដោះលែង (យ៉ាងហោចណាស់៦ខែ)។ | | | X | X | X | X | X | X | មន្ទីរសង្គមកិច្ច | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 3.2.4. | ចូលរួមជាមួយវិស័យឯកជន និង ទីភ្នាក់ងារជាតិការងារ ដើម្បីលើកទឹកចិត្តឱ្យជ្រើសរើសអតីតជនល្មើសចូលបម្រើការងារ។ | | | X | X | X | X | X | X | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | |